# កិច្ចប្រតិបត្តិទូទៅក្នុងការប្រមូលបំណុលដែល មានការទទួលខុសត្រូវ និងប្រកបដោយ កាយវិការសីលធម៌

ខែ សីហា ឆ្នាំ ២០០៩

រក្សាការសម្ងាត់ និងរក្សាសិទ្ធិ

រាល់ការប្រើឯកសារនេះដោយគ្មានការអនុញ្ញាតិពី McKinsey & Company  ត្រូវបានហាមឃាត់ដាច់ខាត

McKinsey&Company

# ការកំណត់អំពីការប្រមូលបំណុលប្រកបដោយកាយវិការសីលធម៌

**ការប្រមូលបំណុលប្រកបដោយសីលធមិអាចត្រូវបានកំណត់ថាជាការថ្លឹងថ្លែងតុល្យភាពនូវសមាធាតុចំនួនបី៖**

**តើអ្វីដែលប្រសើរបំផុតសម្រាប់អ្នកខ្ចីប្រាក់?**

- ព្រំដែននៃការប្រមូលបំណុលធានាឱ្យមានការការពារ និងការគោរពសិទ្ធិរបស់អតិថិជន
- ការប្រមូលបំណុលប្រកបដោយសីលធមិពុំមែនមានន័យថា "ទន់ជ្រាយ" ចំពោះកាប្រមូលបំណុល ឬមិនព្យាយាមប្រមូលបំណុលនោះទេ

**តើអ្វីដែលប្រសើរបំផុតចំពោះស្ថាប័ន?**

- កិច្ចប្រឹងប្រែងប្រមូលបំណុលដោយជោគជ័យមានសារៈសំខាន់ណាស់ ក្នុងការរក្សាបាននូវលទ្ធភាពបានទទួលឥណទាន
- ប្រសិនបើគ្មានការប្រមូលបំណុលដោយជោគជ័យទេនោះ គ្រឹះស្ថានចំណាយច្រើន ធ្វើឱ្យតម្លៃនៃការផ្តល់ឥណទានកើនឡើង ហេតុនេះធ្វើឱ្យប៉ះពាល់ដល់បរិមាណផ្តល់ឥណទានជារួម

**តើអ្វីដែលប្រសើរបំផុតចំពោះទីផ្សារ?**

- វិធីប្រមូលបំណុលចាំបាច់ត្រូវអនុវត្តដោយទទួលស្គាល់នូវអត្ថិភាពនៃទីផ្សារទូទៅ និងទំនាក់ទំនងទៅវិញទៅមករវាងគ្រឹះស្ថាននានា
- គោលបំណងរបស់យើងគឺធ្វើយ៉ាងណាឱ្យសកម្មភាពប្រមូលបំណុលគាំទ្រការគ្រប់គ្រងជារួមចំពោះហានិភ័យដែលមានលក្ខណៈជាប្រព័ន្ធ

# មានដំណើរការប្រមូលបំណុលចំនួន ៦ ដំណាក់កាល ដែលទាក់ទងជាមួយការប្រមូលបំណុលប្រកបដោយកាយវិការសីលធម៌

**1 កិច្ចព្រមព្រៀងជំហានដំបូង**

- កិច្ចព្រមព្រៀងជំហានដំបូងរវាងអតិថិជន និងអ្នកផ្ដល់ឥណទាន

**2 ការពិនិត្យមុនពេលបំណុលហួសកាលកំណត់ និងការញែកចេញពីគ្នា**

- សកម្មភាពចាត់វិធានការជាមុនចំពោះគណនីដែលមានហានិភ័យខ្ពស់ដើម្បី បញ្ចៀសបំណុលហួសកាលកំណត់
- ការញែកអ្នកខ្ចីប្រាក់ចេញពីគ្នាលើមូលដ្ឋាននៃលក្ខណៈហានិភ័យ

**3 ទំនាក់ទំនងអ្នកខ្ចីប្រាក់**

- ព្យាយាមទំនាក់ទំនងជាមួយអ្នកខ្ចីប្រាក់ដោយទូរស័ព្ទ អ៊ីម៉ែល លិខិតប្រៃសណីយ៍ និងការជួបគ្នាដោយផ្ទាល់

**4 យុទ្ធសាស្ត្រ/ប្រព្រឹត្តកម្មប្រមូលបំណុល**

- ផ្ដល់ជម្រើសឱ្យ និងចរចាជាមួយអ្នកខ្ចីប្រាក់ដើម្បីកែកុមគណនី ( ដូចជាផែនការទូទាត់ជាដើម)

**5 វិធានការស្ដារឡើងវិញ**

- ប្រឹងប្រែងប្រមែប្រមូលបំណុលក្រោយពេលមិនអាចប្រមូលបាន
- ការដកហូតយកទ្រព្យសម្បត្តិ ( ការប្ដឹងរឹបអូសសម្បត្តិទ្រព្យ REO ។ល ។

**6 ចំណងទាក់ទងរវាងគ្រឹះស្ថានឱ្យខ្ចីនិងទីភ្នាក់ងារប្រមូលបំណុល**

- គ្រឹះស្ថានផ្ដល់ឥណទានប្រគល់ប្រតិបត្តិការប្រមូលបំណុលឱ្យភ្នាក់ងារប្រមូលបំណុលមកពីខាងក្រៅជាអ្នកអនុវត្ត

# ដំណាក់កាលនីមួយៗលើកឡើងនូវសក្ដានុពលនៃបញ្ហាសីលធម៌

**1**

**កិច្ចព្រមព្រៀងដំបូងរបស់អ្នកខ្ចី**

- ការផ្ដល់ព័ត៌មានស្ដីពីការប្រមូលបំណុលមិនពេញលេញ ឬធ្វើឱ្យមានការយល់រច្ចឡំ

**2**

**ការពិនិត្យមុនពេលបំណុលហួសកាលកំណត់ និងការវៀចចេញពីគ្នា**

- ការរៀបចំសារវតារ
- សកម្មភាពចុះពិនិត្យអ្នកខ្ចីប្រាក់ដែលគ្មានការខ្លាចរអា
- ការឱ្យខ្ចីមិនសមស្រប

**3**

**ទំនាក់ទំនងអ្នកខ្ចីប្រាក់**

- សកម្មភាពចុះពិនិត្យតាមទូរស័ព្ទ ជួបគ្នាជាក់ស្ដែង អ៊ីម៉េល ដែលគ្មានការខ្លាចរអា /មិនសមស្រប
- ខ្លឹមសារប្រាស្រ័យទាក់ទងមិនសមស្រប
- គ្មានភាពជាតំណាង
- មិនអើពើចំពោះសំណើផ្ដល់សុពលភាព
- មិនអើពើចំពោះភាពជាតំណាងតាមផ្លូវច្បាប់

# ដំណាក់កាលនីមួយៗលើកឡើងនូវសក្តានុពលនៃបញ្ហាសីលធម៌ -ត

**4 យុទ្ធសាស្ត្រ/ប្រព្រឹត្តកម្មប្រមូលបំណុល**

- ការផ្តល់ឱ្យមិនសមស្រប ឬការផ្តល់ព័ត៌មានដែលធ្វើឱ្យមានការយល់ ខុស
- ការចរចាដែលមិនត្រឹមត្រូវ
- ទំនាក់ទំនងជាមួយតតិយភាគី
- ថ្លៃសេវាយ៉ាងខ្ពស់ចំពោះភាពយឺតយ៉ាវ ស្វែងរកបរិមាណដោយគ្មានវិចារណកម្ម
- ការណែនាំមិនគ្រប់គ្រាន់ ឬកត្តាលើកទឹកចិត្តដែលរៀបចំមិនត្រឹមត្រូវ
- ផលប៉ះពាល់អវិជ្ជមានចំពោះអ្នកខ្ចី

**5 វិធានការស្តារឡើងវិញ**

- អ្នកខ្ចីមានការអប់រំអំពីឥណទានមិនបានល្អ
- ការដកហូតទ្រព្យសម្បត្តិដោយគ្មានវិចារណកម្ម
- ការដកហូតទ្រព្យសម្បត្តិដែលអនុវត្តមិនសមស្រប

**6 ចំណងទាក់ទងរវាងគ្រឹះស្ថានឱ្យខ្ចី និងទីភ្នាក់ងារប្រមូលបំណុល**

- ប្រគល់ឱ្យទីភ្នាក់ងារប្រមូលបំណុលដោយគ្មានសីលធម៌
- គ្រឹះស្ថានផ្តល់សេវាឥណទាន ទទួលយកការប្រមូលបំណុលដោយគ្មានសីលធម៌
- ផ្តល់កត្តាលើកទឹកចិត្តមិនត្រឹមត្រូវ
- ភាពជាតំណាងមិនត្រឹមត្រូវ

# ឧទាហរណ៍អំពីការប្រមូលបំណុលដែលនាំដល់ក្តីអន្តរាយ

BEAR STEARNS

បានដោះស្រាយទឹកប្រាក់ ២៨ លានដុល្លារ នៅពេលរងការចោទប្រកាន់អំពីបរិមាណទឹកប្រាក់ជំពាក់មិនត្រឹមត្រូវចំពោះអ្នកខ្ចី ដោយយកថ្លៃសេវាដែលគ្មានការអនុញ្ញាតិ និងការពាក់ព័ន្ធជាមួយការប្រមូលបំណុលមិនស្របច្បាប់ និងការប្រមូលបំណុលដែលមានចរិតរំលោភបំពាន ។

ខែ កញ្ញា ឆ្នាំ ២០០៨

Countrywide Financial

រងការប្តឹងផ្តល់ចំពោះការសាងភស្តុតាង ( ភាពខុសគ្នានៃបញ្ជីក្នុងដៃតតិយជន) ដែលត្រូវបានប្រើក្នុងការដេញថ្លៃមួយដើម្បីរឹបយកផ្ទះមួយកន្លែង ។

ខែ មករា ឆ្នាំ ២០០៨

American Home Mortgage

រងការប្តឹងផ្តល់ចំពោះការលក់ផ្ទះនានាយ៉ាងឆាប់រហ័សនៅក្នុងសំណុំកិច្ចសន្យាខ្ចីប្រាក់ទិញផ្ទះ ក្នុង" តម្លៃថោកមិនសមរម្យ " ដើម្បីយកទៅសងបំណុល ។

ខែ កុម្ភៈ ឆ្នាំ ២០០៩

# ការប្រៀបធៀបអំពីការប្រមូលបំណុលនៅបណ្ដាប្រទេសក្នុងករណីសិក្សា

| | លទ្ធផលឧស្សាហកម្ម | | កម្លាំងជម្រុញអំពីការអនុវត្តសីលធម៌ | | កត្តាជម្រុញក្រៅពីបទប្បញ្ញត្តិនៃការអនុវត្តសីលធម៌ | |
|---|---|---|---|---|---|---|
| | ការប្រមូលបំណុលប្រកបដោយសីលធម៌ | ភាពចាស់ទុំនៃទីផ្សារឥណទាន | ភាពពេញលេញនៃបទប្បញ្ញត្តិ | ការអនុវត្តបទប្បញ្ញត្តិ | កម្លាំងសមាគមនៃឧស្សាហកម្ម | សារៈសំខាន់ នៃកេរ្តិ៍ឈ្មោះ |
| សហរដ្ឋអាមេរិក | ● | ● | ● | ● | ◑ | ◕ |
| ចក្រភពអង់គ្លេស | ● | ● | ● | ◕ | ◔ | ◕ |
| កាណាដា | ◕ | ● | ◕ | ● | ● | ◕ |
| ឥណ្ឌា | ◑ | ◑ | ● | ◔ | ○ | ◔ |
| ប្រេស៊ីល | ◑ | ◑ | ◔ | ◑ | ● | ◕ |
| រុស្ស៊ី | ◔ | ◑ | ○ | ○ | ◔ | ○ |

# និន្នាការរួមនៃការប្រមូលបំណុលនៅសហរដ្ឋអាមេរិក

***របកគំហើញរួមៈ***

ជាទូទៅ សហរដ្ឋអាមេរិកតំណាង ការអនុវត្តសឹងតែប្រសើរបំផុតនៅលើផ្នែកភាគច្រើនក្នុងខ្សែសង្វាក់ប្រមូលបំណុល

អនុលោមតាមច្បាប់សហព័ន្ធ ដោយសារភាពចាស់ទុំនៃប្រព័ន្ធច្បាប់ និងការត្រួតពិនិត្យម៉ត់ចត់ចំពោះវិស័យហិរញ្ញវត្ថុ ទន្ទឹមគ្នាជាមួយការគ្រប់គ្រងកេរ្តិ៍ឈ្មោះ ជម្រុញឱ្យមានការអនុវត្តបែបសីលធម៌

## ***របកគំហើញនៅក្នុងផ្នែកនានានៃខ្សែសង្វាក់តម្លៃៈ***

- ***ការពិនិត្យមុនពេលបំណុលហួសកាលកំណត់ និងការញែកចេញពីគ្នា***ការឱ្យខ្ចីដែលមានលក្ខណៈរើសអើង ឬមិនសមស្របត្រូវបានគ្រប់គ្រងយ៉ាងម៉ត់ចត់ដោយអាជ្ញាធររដ្ឋាភិបាល និងត្រូវបានពន័យយ៉ាងធ្ងន់
- ***ទំនាក់ទំនងជាមួយអ្នកខ្ចី***។ ច្បាប់ស្តីពីការប្រមូលបំណុលត្រឹមត្រូវលើកឡើងយ៉ាងពេញលេញនូវបញ្ហាសីលធម៌ដែលពាក់ព័ន្ធនឹងបញ្ហាសីលធម៌ក្នុងការទំនាក់ទំនងជាមួយអ្នកខ្ចី
- ***យុទ្ធសាស្ត្រ/ប្រព្រឹត្តកម្មប្រមូលបំណុល***ស្ថាប័នឱ្យខ្ចីជាច្រើនផ្តល់ប្រព្រឹត្តិកម្មមាលក្ខណៈធូរស្រាលជាងច្បាប់តម្រូវ ដើម្បីរក្សាចំណងទាក់ទងរយៈពេលវែងជាមួយអ្នកខ្ចី ។ គ្មានការតម្រូវឱ្យមានរចនាសម្ព័ន្ធកម្មវិធីសិក្សា ឬកត្តាលើកទឹកចិត្តពីសហព័ន្ធឡើយ ប៉ុន្តែអ្នកប្រមូលបំណុលភាគច្រើន គ្រឹះស្ថានចងការប្រាក់ និងទីភ្នាក់ងារនានាត្រូវមានអាជ្ញាប័ណ្ណ និង/ឬការបណ្តុះបណ្តាល ហើយរួមបញ្ចូលនូវ "ដំណោះស្រាយត្រឹមត្រូវ" ទៅក្នុងគំរូផ្តល់ការលើកទឹកចិត្តនានាចំពោះអ្នកខ្ចី
- ***វិធានការស្តារឡើងវិញ***។ វិធានការស្តារអនុវត្តចំពោះអ្នកខ្ចី ត្រូវបានគ្រប់គ្រងដោយច្បាប់របស់រដ្ឋ និងប្រែប្រួលទៅតាមប្រភេទអចលកម្ម ។ ច្បាប់ទាំងនោះតម្រូវឱ្យអ្នកប្រមូលបំណុលបញ្ជូនសេចក្តីជូនដំណឹងគ្រប់គ្រាន់ និងអនុវត្តតាមដំណើរការស្តារស្ថានភាពដែលមានតម្លាភាព ដោយបញ្ជាក់សិទ្ធិរបស់អ្នកខ្ចីឱ្យបានច្បាស់លាស់

# ទិដ្ឋភាពរួមនៃការប្រមូលបំណុលនៅឥណ្ឌា

### *របកគំហើញទូទៅ*

បទប្បញ្ញត្តិមានលក្ខណៈស្រដៀងសហរដ្ឋអាមេរិក ប៉ុន្តែការប្រព្រឹត្តិដែលគ្មានសីលធម៌នៅតែមានជាទូទៅ ដោយសាររដ្ឋាភិបាលត្រួតពិនិត្យមិនបានល្អ មានការជម្រុញឱ្យការពារអតិថិជនតិចតួច ហើយប្រព័ន្ធច្បាប់គ្មានប្រសិទ្ធិភាព

ថ្មីៗនេះ ដោយសារមានសម្ពាធពីអន្តរជាតិ ធនាគារបម្រុងរបស់ឥណ្ឌាបានចាប់ផ្តើមផាកពិន័យយ៉ាងច្រើនចំពោះអំពើល្មើសក្នុងការប្រមូលបំណុល

សព្វថ្ងៃអន្តរកាលឧស្សាហកម្មចំបងមួយកំពុងប្រព្រឹត្តទៅ

### *របកគំហើញនៅក្នុងផ្នែកផ្សេងៗនៃខ្សែសង្វាក់តម្លៃ*

- ***ការពិនិត្យមុនពេលបំណុលហួសកាលកំណត់ និងការរំឭកចេញពីគ្នា***។ បញ្ហាទូទៅភាគច្រើនពាក់ព័ន្ធនឹងគ្រឹះស្ថានឱ្យខ្ចីចងការដែលមិនបានបោះផ្សាយកាលកំណត់ និងថ្លៃឥណទានជាភាសានៃរដ្ឋនៅមូលដ្ឋាន ។ ជាទូទៅគ្មានការពិនិត្យមុនពេលបំណុលហួសកាលកំណត់ឡើយ ។
- ***ទំនាក់ទំនងជាមួយអ្នកខ្ចី***។ ការរំលោភភាគច្រើនៗតែទាក់ទងអ្នកខ្ចីនៅពេលវេលាមិនសមស្រប ហើយជួលជើងកាងនៅក្នុងស្រុកឱ្យគំរាមអ្នកខ្ចីប្រាក់នៅកន្លែងធ្វើការ ឬនៅតាមផ្ទះ ។
- ***យុទ្ធសាស្ត្រ/ប្រព្រឹត្តកម្មប្រមូលបំណុល***។ បទប្បញ្ញត្តិនានាចែងថា អ្នកប្រមូលបំណុលមិនត្រូវគំរាម មិនត្រូវរេបីអំពើហឹង្សារលើរាងកាយ មិនត្រូវទំនាក់ទំនងជាមួយភាគីទីបី ឬទាមទារឱ្យសងប្រាក់មិនត្រឹមត្រូវ ។ ខណៈដែលទីភ្នាក់ងារភាគច្រើនមិនពាក់ព័ន្ធជាមួយការរំលោភបំពានលើបទប្បញ្ញត្តិទាំងនេះ គេដឹងថាសកម្មភាពប្រមូលបំណុលដែលអនុវត្តដោយអ្នកផ្សេងដោយប្រើជើងកាង បានប្រើបច្ចេកទេសទាំងនេះ ។ ធនាគារបម្រុងរបស់ឥណ្ឌាតម្រូវឱ្យអ្នកប្រមូលបំណុលមានវិញ្ញាបនប័ត្របណ្តុះបណ្តាល ប៉ុន្តែពុំសូវមានការគោរពតាម ហើយគ្មានកម្មវិធីសិក្សាដែលមានលក្ខណៈស្តង់ដារឡើយ ។ គ្មានការផ្តល់ការអប់រំផ្នែកហិរញ្ញវត្ថុចំពោះអ្នកខ្ចីឡើយ ។
- ***វិធានការស្តារ និងចំណងទាក់ទងរវាងគ្រឹះស្ថានឥណទាន និងទីភ្នាក់ងារប្រមូលបំណុល*** មានបញ្ហាជាមួយ អ្នកប្រមូលបំណុល ដែលដក់ហូតទ្រព្យសម្បត្តិមិនសមស្រប ហើយពឹងផ្អែកលើជើងកាងដែលប្រើអំពើ ហឹង្សា

# ការប្រៀបធៀបកិច្ចប្រតិបត្តិនៅទីផ្សារអភិវឌ្ឍ និងទីផ្សាររីកចម្រើនថ្មី

## មេរៀនសំខាន់ៗដែលបានរៀនសូត្រពីករណីសិក្សានានា

- ជាទូទៅ **អ្នកប្រមូលបំណុលនៅទីផ្សារកាន់តែអភិវឌ្ឍ កាន់តែពិចារណាអំពីបញ្ហាសីលធម៌ ហើយដាក់បញ្ចូលទៅក្នុងប្រតិបត្តិការនានា** ច្រើនជាង អ្នកប្រមូលបំណុលនៅទីផ្សាររីកចម្រើនថ្មី។ ច្បាប់នៅប្រទេសនីមួយៗមិនដូចគ្នាឡើយ ប៉ុន្តែនៅប្រទេសអភិវឌ្ឍន៍ មានគោលការណ៍ណែនាំស្រដៀងគ្នាសម្រាប់ដោះស្រាយការប្រមូលបំណុលប្រកបដោយសីលធម៌

- **ការប្រមូលបំណុលនៅទីផ្សាររីកចម្រើនថ្មីមានភាពមិនដូចគ្នា**ជាខ្លាំង។ ទោះបីជាមានពេលដែលការប្រព្រឹត្តកើតឡើងដោយគ្មានការទទួលខុសត្រូវជាទូទៅក្តី ក៏ការប្រព្រឹត្តិបែបនេះកើតមានជាច្រើនលើក និងក្នុងភាពតានតឹង

- **ភាពខុសគ្នាលើបរិបទនយោបាយ និងបរិបទច្បាប់ធ្វើឱ្យមានភាពខុសគ្នាអំពីការអនុវត្តនៅទីផ្សារអភិវឌ្ឍន៍ និងទីផ្សាររីកចម្រើនថ្មីៗផងដែរ**។ ច្បាប់ពេញលេញដែលគាំទ្រដោយយន្តការអនុវត្តដែលមានភាពចាស់ទុំ បានជួយណែនាំការប្រមូលបំណុលនៅក្នុងពិភពអភិវឌ្ឍន៍

- **សមាគមឧស្សាហកម្មបានបំពេញតួនាទីទាំងស្រុង** ក្នុងការផ្តល់ធនធាន និងការគាំទ្រដើម្បីអនុវត្តតាមស្តង់ដារទទួលខុសត្រូវ។ នៅក្នុងទីផ្សាររីកចម្រើនថ្មី សមាគមទាំងនេះបានចាប់ផ្តើមបំពេញចំណុចខ្វះខាតក្នុងការអនុវត្តបទប្បញ្ញត្តិ

# គោលការណ៍ណែនាំសម្រាប់ការប្រមូលបំណុលប្រកបដោយសីលធម៌ និងការទទួលខុសត្រូវ

1 វិនិយោគលើចំណោងទាក់ទងប្រកបដោយតម្លាភាពជាមួយអ្នកខ្ចី

2 ប្រាស្រ័យទាក់ទងជាមួយអតិថិជនក្នុងបែបមួយត្រឹមត្រូវ និងដោយក្តីគោរព

3 បង្កើតប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ និងចំណោងទាក់ទងជាមួយភាគីពាក់ព័ន្ធខាងក្រៅ ដើម្បីគាំទ្រកិច្ចប្រតិបត្តិប្រកបដោយសីលធម៌

# គោលការណែនាំទី ១: ឧទាហរណ៍អំពីការប្រព្រឹត្តិ

**1** ***វិនិយោគលើចំណងទាក់ទងប្រកបដោយតម្លាភាពជាមួយអ្នកខ្ចី***

- ផ្តល់ព័តិមានអំពីការឱ្យខ្ចីចងការ និងការប្រមូលបំណុលទាំងឡាយបានច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងដើមរបស់អ្នកខ្ចី
- អប់រំអ្នកខ្ចីអំពីវិធីនានាដើម្បីជៀសវាងបំណុលហួសកាលកំណត់ក្នុងពេលអនាគត
- ផ្តល់ជម្រើសជាមុនដែលមានលក្ខណៈសមរម្យ មានតម្លាភាពចំពោះអ្នកខ្ចី ដើម្បីជៀសវាងលទ្ធភាពនៃការជំពាក់បំណុលច្រើនហួស ឬដើម្បីជៀសវាងការដកហូតទ្រព្យសម្បត្តិ

# គោលការណ៍ណែនាំទី ២៖ ឧទាហរណ៍អំពីការប្រព្រឹត្តិ

2 ប្រាស្រ័យទាក់ទងជាមួយអតិថិជនក្នុងបែបមួយត្រឹមត្រូវ និងដោយការគោរព

- មិនត្រូវរើសអើង
- មិនត្រូវទំនាក់ទំនងជាមួយអ្នកខ្ចីដោយញឹកញាប់មិនសមហេតុផល
- ចូរទំនាក់ទំនងអ្នកខ្ចីប្រាក់តាមពេលម៉ោងសមស្រប
- មិនត្រូវប្រើអំពើហឹង្សាលើរាងកាយ ឬគំរាមកំហែង ឬភាសាអសុរសឡើយ
- មិនត្រូវបញ្ចេញព័តិមានអំពីបំណុលទៅកាន់ភាគីទីបី

# គោលការណ៍ណែនាំទី ៣៖ ឧទាហរណ៍អំពីការប្រព្រឹត្តិ

**3**

***បង្កើតប្រព័ន្ធ បែងចែកធនាសម្ព័ន្ធ និងចំណងទាក់ទងជាមួយភាគីពាក់ព័ន្ធខាងក្រៅ ដើម្បីគាំទ្រកិច្ចប្រតិបត្តិប្រកបដោយសីលធម៌***

- មិនត្រូវប្រគល់ឱ្យអ្នកផ្សេងប្រមូលបំណុលដោយកាយវិការអសីលធម៌នោះទេ
- មិនត្រូវប្រើប្រាស់ស្ថាប័នច្បាប់ ឬនយោបាយដើម្បីអនុគ្រោះចំពោះការប្រព្រឹត្តិដែលគ្មានការទទួលខុសត្រូវ ឬដែលគ្មានសីលធម៌
- បង្កើតប្រព័ន្ធផ្ទៃក្នុងដើម្បីត្រួតពិនិត្យ ដើម្បីធានាអនុលោមភាពជាមួយការណែនាំលើផ្នែកសីលធម៌
- បណ្តុះបណ្តាលអ្នកប្រមូលបំណុល លើការប្រព្រឹត្តិប្រកបដោយកាយវិការសីលធម៌ និងលើកទឹកចិត្តឱ្យមានការទទួលខុសត្រូវ

# អាចមានគំរូចំនួនបួនយ៉ាងសម្រាប់លើកទឹកចិត្តក្នុងការប្រើប្រាស់ស្តង់ដារសីលធម៌

**បទប្បញ្ញត្តិ**
- ផ្តល់នូវកម្រិតគ្រប់គ្រងខ្ពស់បំផុតក្នុងការកំណត់ការប្រព្រឹត្តិ ដែលអាចទទួលយកបាន
- ជោគជ័យអាស្រ័យលើរដ្ឋាភិបាល និងការអនុវត្តច្បាប់ (ដូចជា ការផាកពិន័យជាដើម)

**សមាគមឧស្សាហកម្ម**
- គំរូគឺការជ្រើសយក ហើយពាក់ព័ន្ធជាមួយការអនុវត្តដោយខ្លួនឯងជាជាងដោយបទប្បញ្ញត្តិ

**ការជម្រុញដោយខ្លួនឯង (ការគ្រប់គ្រងហានិភ័យអំពីកេរ្តិ៍ឈ្មោះ)**
- ស្តង់ដារសីលធម៌ដែលដាក់ឱ្យខ្លួនឯងអនុវត្ត
- មានការត្រួតពិនិត្យតិចបំផុតចំពោះការប្រព្រឹត្ត ដែលអាចទទួលយកបាន

**""ត្រាឯកភាព"**
- ស្ថាប័នឯករាជ្យមួយដែលកសាងការប្រព្រឹត្តិដែលអាចទទួលយកបាន និងចាត់ថ្នាក់អ្នកប្រមូលបំណុលលើអនុលោមភាព
- ជម្រុញឱ្យមានសមត្ថកិច្ចមិនលំអៀង និងដាក់សម្ពាធមកលើឧស្សាហកម្មដើម្បីឱ្យមានអនុលោមភាព
- ជូនកាលប្រព័ន្ធផ្សព្វផ្សាយដើរតួក្រៅផ្លូវការ

# ការអនុវត្តតាមគោលការ "គោលការណ៍នៃការប្រមូលបំណុលដោយការយវិការសីលធម៌" មានសក្តានុពលក្នុងការ បង្កើតតម្លៃសម្រាប់អ្នកប្រមូលបំណុលផងដែរ

## ផលប្រយោជន៍

- មានពាក្យបណ្តឹងតិចតួចពីអ្នកខ្ចី
- មានការផាកពិន័យតិចតួចចំពោះការប្រព្រឹត្តិល្មើសបទប្បញ្ញត្តិ
- អាចមានទឹកប្រាក់ទូទាត់យ៉ាងច្រើន
- វិធានការស្តារដែលត្រូវចំណាយខ្ពស់ មានចំនួនតិចតួច (ដូចជាប្តឹងរឹបអូសសម្បត្តិទ្រព្យពីកូនបំណុល ជាដើម)
- លើកកំពស់កេរ្តិ៍ឈ្មោះក្នុងចំណោមអ្នកខ្ចីដែលមានសក្តានុពល
- កាត់បន្ថយការប៉ះទង្គិចជាមួយអ្នកខ្ចីបច្ចុប្បន្ន

## ការខាតបង់

- អាចមាន RPCs កាន់តែតិច
- មានការចរចា និងជម្រើសដំណោះស្រាយតិចតួច
- អាចស្តារបានតិចតួច
- ចំណាយខ្ពស់លើការបណ្តុះបណ្តាល និងចំណាយពាក់ព័ន្ធនឹងកត្តាលើកទឹកចិត្ត
- នីតិវិធីខ្ពស់អំពីស្តារចំណាយ

# ជំហានបន្ទាប់

- តើគោលការណ៍ណែនាំអាចត្រូវបានប្រើយ៉ាងដូចម្ដេច សម្រាប់ធ្វើជាមូលដ្ឋានដើម្បីបង្កើតស្តង់ដារទូទៅ សម្រាប់ការប្រមូលបំណុលនៅទូទាំងពិភពលោក?

- តើមានផលប៉ះពាល់អ្វីខ្លះអំពីស្តង់ដារប្រមូលបំណុលប្រកបដោយកាយវិការសីលធម៌ចំពោះចំណាត់ថ្នាក់អចលកម្មផ្សេងគ្នា?

- តើយើងអាចកៀងគរ និងសម្រួលការពិភាក្សាទូលាយជាមួយក្រុមភាគីពាក់ព័ន្ធនានា ដើម្បីកសាងមាគ៌ាសម្រាប់អនុវត្ត?